ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.....១០០១.......សហវ.....

# ប្រកាស

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋាន

## នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០០៧ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងលើភាពចាំបាច់របស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សំរេច

**ប្រការ ១.-**

បង្កើត **"លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"** ហៅកាត់ **"លគហស"** ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- លោក **សុខ សារាទុឡ** | ប្រធាន |
| ២- លោក **យក់ ប៊ុនណា** | អនុប្រធាន |
| ៣- លោក **ប៊ុន វុត្ថ** | មន្ត្រីសម្របសម្រួលកម្មវិធី |
| ៤- លោក **ប៊ូ ចន្ទ្រសុខា** | មន្ត្រីសម្របសម្រួលកម្មវិធី |
| ៥- លោក **អៀង អូនឌូច** | មន្ត្រីទំនាក់ទំនង |
| ៦- លោក **ប៉ូ ឫទ្ធី** | មន្ត្រីទំនាក់ទំនង |
| ៧- លោក **នុប សុធនវិចិត្រ** | មន្ត្រីទំនាក់ទំនង |
| ៨- លោកស្រី **គីម ចន្ទ្រនគន្ធារី** | មន្ត្រីទំនាក់ទំនង |
| ៩- លោក **នួន ទិត្យ៉ា** | មន្ត្រីទំនាក់ទំនង |
| ១០-លោក **ហ៊ែល ចំរើន** | មន្ត្រីជំនួយកិច្ចការទំនាក់ទំនង |
| ១១-លោក **យ៉េត ទីណែល** | មន្ត្រីជំនួយកិច្ចការទំនាក់ទំនង |
| ១២-លោក **សុខ លីណា** | មន្ត្រីជំនួយកិច្ចការទំនាក់ទំនង |
| ១៣-លោកស្រី **គង់ សុធីរ** | គណនេយ្យករ |
| ១៤-លោក **សៀង គង់** | មន្ត្រីលទ្ធកម្ម |

**ប្រការ ២.-**

លេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានមុខងារ និងភារកិច្ចដូចតទៅ:

- ធ្វើជាសេនាធិការបច្ចេកទេសរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការរៀបចំ និងតាមដានការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- គ្រប់គ្រង និង ទទួលខុសត្រូវលើរាល់ការងារ រដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ

លទ្ធកម្ម និង រាល់ការងារទំនាក់ទំនងជាមួយ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សា អ្នកជំនាញការ ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមការដឹកនាំរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

- ធ្វើជាចំណុចប្រមូលផ្តុំ ក្នុងការផ្តល់ប្រឹក្សា ផ្តល់ការសម្របសម្រួល និងផ្តល់ការណែនាំផ្សេងៗពាក់ព័ន្ធនឹងការរៀបចំ និងការតាមដានត្រួតពិនិត្យ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយក្រសួង ស្ថាប័ន ជាពិសេសក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំង នាយកដ្ឋាន និង អង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ធ្វើជាចំណុចប្រមូលផ្តុំ ក្នុងការបូកសរុបរបាយការណ៍ពីគ្រប់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួង ស្ថាប័ន និងពីនាយកដ្ឋាននិងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ ៣.-**

ប្រធាន អនុប្រធាន ព្រមទាំងមន្ត្រីទាំងអស់ នៃ **"លគហស"** បំពេញការងារទៅតាមលក្ខខណ្ឌការងារ និងទទួលលាភការតាមលទ្ធផលការងារតាមរយៈការចុះកិច្ចសន្យាការងារដែលសម្រេចដោយប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ លាភការតាមលទ្ធផលការងារដែលផ្តល់ដល់ ប្រធាន អនុ-ប្រធាន និងមន្ត្រីនៃ **"លគហស"** គឺផ្អែកតាមអត្រាលាភការពិសេសដែលមានការព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងអាស្រ័យលើគុណវុឌ្ឍិសិក្សា និងបទពិសោធន៍ការងាររបស់មន្ត្រីដែលត្រូវបានជ្រើសរើស។

**ប្រការ ៤.-**

ផ្អែកតាមតម្រូវការការងារ **"លគហស"** អាចជ្រើសរើសមន្ត្រីតាមកិច្ចកិច្ចសន្យាដែលមិនមែនជាមន្ត្រីរាជការ ដើម្បីបំពេញការងារនៅក្នុង **"លគហស"** ដោយមានការឯកភាពពីប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ ៥.-**

មន្ត្រីនៃ **"លគហស"** ទាំងអស់រួមទាំងមន្ត្រីតាមកិច្ចសន្យា ត្រូវបំពេញការងារអោយបានម៉ត់ចត់ និងពេញលេញស្របតាមលក្ខខណ្ឌការងារ និង កិច្ចសន្យារបស់សាមីខ្លួន។ ក្នុងករណីដែលមិនបានគោរពតាមលក្ខខណ្ឌការងារ និង កិច្ចសន្យានោះទេ កិច្ចសន្យាការងាររបស់មន្ត្រីនោះ អាចត្រូវបញ្ចប់មុនកាលបរិច្ឆេទកំណត់។

**ប្រការ ៦.-**

មន្ត្រីនៃ **"លគហស"** ទាំងអស់ រួមទាំងមន្ត្រីតាមកិច្ចសន្យា ដែលមានបំណងបញ្ចប់ការងាររបស់ខ្លួន មុនកាលបរិច្ឆេទកំណត់នៅក្នុងកិច្ចសន្យា ឬ មិនមានបំណងបន្តកិច្ចសន្យាការងារតទៅទៀត មន្ត្រីនោះ ត្រូវជូនដំណឹងដល់ប្រធាន **"លគហស"** យ៉ាងហោចរយៈពេល ០២ (ពីរ) ខែជាមុន ។

**ប្រការ ៧.-**

ប្រកាសលេខ ១២២ សហវ-ប្រក ចុះថ្ងៃទី ១៩ ខែកុម្ភៈ ឆ្នាំ ២០០៨ ស្តីពីការបង្កើតលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានចាត់ទុកជានិរាករណ៍។

**ប្រការ ៨.-**

ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែតុលា ឆ្នាំ ២០០៨*

គាត ឈន់

**ចំលងជូន:**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង និង ស្ថាប័ន
- គ្រប់ថ្នាក់ដឹកនាំនៃ កសហវ
- គ្រប់អង្គភាព និងនាយកដ្ឋានក្រោមឱវាទ កសហវ
- សាមីខ្លួន ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ